# ព្រឹត្តិបត្រព័ត៌មាន
## សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ
*Information Bulletin*

The Cambodian Independent Teachers' Association

ឆ្នាំទី០៥ លេខ ៣៤ ចេញផ្សាយ ខែកក្កដា/សីហា ឆ្នាំ២០១១ YERS #05 No.34 ISSUE JULY/AUGUST 2011


# សិក្ខាសាលាស្តីពីការតស៊ូមតិ



*លោកគ្រូអ្នកគ្រូថតរួមគ្នាក្រោយពីបញ្ចប់សិក្ខាសាលាស្តីពីការតស៊ូមតិ នៅខេត្តបាត់ដំបង*

សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ខេត្តបាត់ដំបង បានរៀបចំសិក្ខាសាលាស្តីពីការអប់រំចំណេះដឹងនិងបណ្តុះបណ្តាលការតស៊ូមតិ កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១១ នៅសណ្ឋាគារសេងហួត ខេត្តបាត់ដំបង ក្រោមអធិបតីភាពលោក រ៉ុង ឈុន ប្រធានសមាគម និងលោក ចន ទីប្រឹក្សាសមាគម មានលោកគ្រូអ្នកគ្រូចូលរួមចំនួន ៤៤នាក់ ។

[ តទៅទំព័រទី ៤ ]

**មាតិកា** **ទំព័រ**


◈ សមាគមចូលរួមសមាជរបស់អង្គការអប់រំអន្តរជាតិ --------------------២
◈ លិខិតចំហជូនចំពោះ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ---៣
◈ សមាគមស្នើសុំរាជរដ្ឋាភិបាលតម្លើងប្រាក់បៀវត្សរ៍ជូនដល់គ្រូបង្រៀន... ---------៦
◈ ប្រទេសកម្ពុជា : ការឆ្លុះបញ្ចាំងអំពីសិទ្ធិគ្រូបង្រៀន ------------------៧
◈ សិក្ខាសាលាស្តីពីការបណ្តុះបណ្តាលអំពីការតស៊ូមតិ---------------------៨



**ផ្សាយចេញពីទីស្នាក់ការសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ**
អាសយដ្ឋាន : ផ្ទះលេខ ៥៤ អឺហ្សេរ្យ៉ូ ផ្លូវលេខ ៩៥ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
Fax/Phone : (855 23) 217 544, H/P : (855 12) 930 706, E-mail : cita@online.com.kh
Website : www.cita.org.kh

# សមាគមចូលរួមសមាជរបស់អង្គការអប់រំអន្តរជាតិ

សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA) ត្រូវបានអង្គការអប់រំអន្តរជាតិ (EI) អញ្ជើញឱ្យទៅចូលរួមក្នុងអង្គសមាជ លើកទី ៦ របស់ខ្លួន នៅទីក្រុងខាប់ថោននៃប្រទេសអាហ្វ្រិកខាងត្បូង ( Cupe town of South Africa) កាលពីថ្ងៃទី ២២-២៦ ខែកក្កដា ឆ្នាំ២០១១ ។

អង្គសមាជមានសមាជិកចូលរួមចំនួន ១៨០០នាក់ មកពី ១៥៣ ប្រទេស និង ៣១៥ អង្គការ/សហជីព ទូទាំងពិភពលោក ក្នុងនោះមានសមាគគ្រូបង្រៀនកម្ពុជាឯករាជ្យមួយផងដែរ ។

គោលបំណងនៃអង្គសមាជ គឺបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសម្រាប់អាណត្តិថ្មី និងអនុម័តនូវគោលនយោបាយសម្រាប់អាណត្តិបន្ត ។

លោកស្រី Sunsan Hocgood ត្រូវបានអង្គសមាជបោះឆ្នោតគាំទ្រ លោកស្រីធ្វើជាប្រធានរបស់អង្គការអប់រំអន្តរជាតិសម្រាប់អាណត្តិថ្មី ។

អង្គសមាជ បានធ្វើការជ្រើសរើសប្រទេសចំនួន ៨ ក្នុងនោះមានប្រទេសកម្ពុជាមួយដែរ ដែលអង្គសមាជបានលើកជាគោលដៅយុទ្ធនាការដាក់ចូលក្នុងអង្គសមាជ តាមរយៈការបោះពុម្ព ជា **ប៉ុស្ទ័រ** ចែកជូនដល់សមាជិកដែលអញ្ជើញមកពីបណ្តាប្រទេសនានាចូលរួមក្នុងអង្គសមាជ ។

**ប៉ុស្ទ័រ**ដែលរៀបចំដោយអង្គការអប់រំអន្តរជាតិនោះ បានទាមទារជំរុញឱ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗត្រូវតែគោរពទៅតាមបទដ្ឋានរបស់អង្គការ ILO និងធានានូវសិទ្ធិសេរីភាពរបស់គ្រូបង្រៀន កម្មករ និងជំរុញលើកកម្ពស់ឱ្យមានការអប់រំសម្រាប់ទាំងអស់គ្នា ការពារសេរីភាពសមាគម និង សិទ្ធិចរចារួម ។

ក្នុងឱកាសនោះដែរ អង្គសមាជបានអនុញ្ញាតឱ្យលោកប្រធាន **រ៉ុង ឈុន** ចែកនូវឯកសារស្តីពីស្ថានភាពគ្រូបង្រៀននៅកម្ពុជា ដែលចងក្រងឡើងដោយសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យលើបញ្ហាដែលលោកគ្រូអ្នកគ្រូយើងបានលើកឡើង ក្នុងកិច្ចប្រជុំនិងអង្គសិក្ខាសាលានានាកន្លងមក ។ និងធ្វើបទបង្ហាញអំពីគុណភាពអប់រំនៅកម្ពុជា ។ លោកក៏បានជួបប្រជុំពិភាក្សាជាមួយបណ្តាអង្គការ/សហជីព មកពី អាមេរិក អង់គ្លេស បារាំង កាណាដា អូស្ត្រាលី... ។

គ្រប់ប្រទេសដែលចូលរួមសមាជ គេមានការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះគ្រូបង្រៀននៅកម្ពុជាយើង លើបញ្ហាប្រាក់បៀវត្សរ៍តិច និងបញ្ហាគុណភាពអប់រំ បញ្ហាការរំលោភសិទ្ធិសេរីភាពនៃការជួបប្រជុំរបស់គ្រូបង្រៀនតាមរយៈសមាគម ។ ពួកគេសម្តែងការគាំទ្រដល់គ្រូសមាជិកសមាគម និងសកម្មភាពសមាគម ដែលបានខិតខំតស៊ូយ៉ាងសកម្មក្នុងការការពារសិទ្ធិគ្រូបង្រៀន ការពារផលប្រយោជន៍គ្រូ និងជំរុញការលើកកម្ពស់វិស័យអប់រំនៅកម្ពុជា ។

***ដោយ : CITA***

***នេះជាតារាងប្រៀបធៀបប្រាក់បៀវត្សរ៍គ្រូបង្រៀនកម្ពុជាជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី (លើកលែងប្រទេសឡាវ)***

| | កម្ពុជា | ឡាវ | វៀតណាម | ថៃ | ម៉ាឡេស៊ី | ឥណ្ឌូណេស៊ី | ហ្វីលីពីន |
|---|---|---|---|---|---|---|---|
| គ្រូបឋមសិក្សា | ៥០ ដុល្លារ | ៣៩-៤៥ ដុល្លារ | ១១៧ ដុល្លារ | ៤១៧ ដុល្លារ | ៥០៧ ដុល្លារ | ២១៦ ដុល្លារ | ៣៤៨ ដុល្លារ |
| GDPក្នុង១នាក់/ឆ្នាំ | ៧៩៥ ដុល្លារ | ៨៧៨ ដុល្លារ | ៣១២៣ ដុល្លារ | ៨៦៤៣ ដុល្លារ | ១៤.៩០០ ដុល្លារ | ២២០០ ដុល្លារ | ១៧៤៦ ដុល្លារ |
| ភាពខុសគ្នា -/+ | ០% | -១០% | +១៣៤% | +៨៣៤% | ១០០០% | ៤២៥% | ៦៩៦% |

***GDP : គឺជាផលិតផលសរុបក្នុងមនុស្សម្នាក់ ដែលរកចំណូលបានក្នុងមួយឆ្នាំ***

**សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ**
CAMBODIAN INDEPENDENT TEACHER'S ASSOCIATION

## លិខិតចំហជូនចំពោះ
## រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ

***សម្តេច ឯកឧត្តម លោកជំទាវជាទីគោរព !***

ថ្ងៃនេះ ថ្នាក់ដឹកនាំ សមាជិកសមាជិកានិងសហការីសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ(CITA) បានរៀបចំប្រារព្ធពិធីអបអរសាទរទិវាគ្រូបង្រៀនពិភពលោក ដោយមានការចូលរួមពីគ្រូបង្រៀនមកពីតាមបណ្តាខេត្ត-ក្រុង សិស្ស និស្សិត អណាព្យាបាលសិស្ស និងកម្មករយ៉ាងច្រើនកុះករ ។

ទិវាគ្រូបង្រៀនពិភពលោក គឺជាទិវាអន្តរជាតិមួយត្រូវបានគេប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំនៅថ្ងៃទី០៥ខែតុលា ដើម្បីជាពិធីប្រារព្ធនាទីគ្រូបង្រៀនក្នុងការផ្តល់គុណភាពនៃការអប់រំនៅគ្រប់កម្រិត ។ ហើយវាក៏ជាការប្រារព្ធខួបនៃការចុះហត្ថលេខា នៅក្នុងឆ្នាំ១៩៦៦ នៃអនុសាសន៍របស់អង្គការយូនីស្កូ (UNESCO) និងអង្គការពលកម្មអន្តរជាតិ (ILO) ស្តីពីកម្រិតស្ថានភាពគ្រូបង្រៀនក្នុងការផ្តល់នូវគុណភាពនៃការអប់រំគ្រប់កម្រិត ។

ប្រទេសជាច្រើននៅជុំវិញពិភពលោក បានចាត់ទុកទិវាគ្រូបង្រៀនពិភពលោកជាការផ្តល់ឱកាសឱ្យរដ្ឋាភិបាល និងសង្គមទទួលស្គាល់ពីសារសំខាន់នៃការចូលរួមចំណែករបស់គ្រូបង្រៀន ក្នុងការអភិវឌ្ឍសង្គម ។ សមាគម CITA ចង់ប្រើប្រាស់ការប្រារព្ធទិវាគ្រូបង្រៀនពិភពលោកនេះ ក្នុងគោលបំណងជំរុញរាជរដ្ឋាភិបាល និងជាពិសេសក្រសួងអប់រំឱ្យយកចិត្តទុកដាក់ ចំពោះតួនាទីរបស់គ្រូបង្រៀនដែលមានសារសំខាន់ក្នុងការកសាងអនាគតដ៏ល្អប្រសើរ និងត្រូវទទួលស្គាល់ចំពោះការលើកឡើង របស់សមាគមគ្រូបង្រៀនអំពីកង្វល់នៃការធ្លាក់ចុះនូវវិស័យអប់រំនាពេលបច្ចុប្បន្ននេះ ។

តាំងតែពីសមាគម CITA បានបង្កើតឡើងនៅឆ្នាំ២០០០មក សមាគម និងសមាជិករបស់ខ្លួនបានចូលរួមខិតខំធ្វើការយ៉ាងសកម្មក្នុងការលើកកម្ពស់គុណភាពនៃការអប់រំ និងបង្កើនសមត្ថភាពធនធានប្រជាពលរដ្ឋកម្ពុជា ដើម្បីធានាបានការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា ថ្វីបើគ្រូបង្រៀនកំពុងបានប្រឈមមុខទៅនឹងបញ្ហាជាច្រើនប្រចាំថ្ងៃក៏ដោយ ។

នៅក្នុងឱកាសអបអរសាទរទិវាគ្រូបង្រៀនពិភពលោកឆ្នាំ២០១១ សមាគមគ្រូបង្រៀកម្ពុជាឯករាជ្យ សូមដាក់សំណើមួយចំនួនជូនថ្នាក់ដឹកនាំនៃស្ថាប័នរដ្ឋរួមមាន រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបានពិចារណាយកចិត្តទុកដាក់គិតគូរនិងដោះស្រាយ ដូចខាងក្រោម :

១-តម្លើងតម្លៃឯកតានៃសន្ទស្សន៍បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល (គ្រូបង្រៀន) ឱ្យបានចំនួន ៣៥០០រៀល ក្នុងមួយសន្ទស្សន៍ នៅដើមឆ្នាំ២០១២ និងដល់ឆ្នាំ២០១៥ ឱ្យបាន ៦៧០០រៀល ក្នុងមួយសន្ទស្សន៍

២-ផ្លាស់ប្តូរទម្រង់ប្រាក់អត្ថប្រយោជន៍ផ្សេងៗរបស់គ្រូបង្រៀន

៣-លើកទឹកចិត្តគ្រូបង្រៀនឱ្យមានការចូលរួមក្នុងគោលនយោបាយអប់រំ និងការគ្រប់គ្រង

៤-ទទួលស្គាល់សិទ្ធិសហជីព និងសិទ្ធិចរចាជាសមូហភាពរបស់គ្រូបង្រៀន

៥-ត្រូវលុបបំបាត់ភាពមិនប្រក្រតីនៅក្នុងវិស័យអប់រំ និងធ្វើឱ្យគុណភាពអប់រំប្រសើរឡើង ។

សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យជឿជាក់ថា ជំនួបពិភាក្សាជាផ្លូវការច្បាស់លាស់មួយ ដែលមានសហជីពគ្រូបង្រៀន រាជរដ្ឋាភិបាល និងសហគមន៍ អាចចូលរួមបានដោយស្មើភាពគ្នា គឺជាកូនសោរដ៏សំខាន់ក្នុងការពង្រឹងប្រព័ន្ធអប់រំបន្ថែមទៀត ។ ក្រៅពីចំណុចនេះផងដែរ សមាគម CITA ចង់ធ្វើឱ្យប្រាដកថាគ្រូបង្រៀនត្រូវបានគោរព និងផ្តល់សំឡេងឱ្យបានពេញលេញគ្រប់ទីកន្លែង ។ ហើយសមាគម CITA ក៏ជឿជាក់ផងដែរថា ការចូលរួមរបស់គ្រូបង្រៀនឱ្យបានច្រើនកុះករជាមួយសមាគម នឹងអាចជួយរកដំណោះស្រាយទៅនឹងបញ្ហាដែលគ្រូបង្រៀនកំពុងប្រឈមមុខជាមួយនាពេលបច្ចុប្បន្ននេះ ។ ហេតុដូច្នេះហើយ ទើបយើងមានសំណើខ្លះ ស្នើទៅកាន់ក្រសួងអប់រំ សូមឱ្យមានកិច្ចសហប្រតិបត្តិការជាមួយគ្នា ដើម្បីជួយរកដំណោះស្រាយ និងលើកកម្ពស់គុណភាពនៃការអប់រំ ។

ទាក់ទងជាមួយបញ្ហាចំនួនប្រាំដែលបានលើកឡើងខាងលើនេះ សមាគម CITA នៅមានសំណើជាច្រើនទៀត ដែលយើងបានរៀបចំរួចរាល់ទុកដើម្បីជជែកពិភាក្សាជាមួយរដ្ឋាភិបាល និងក្រសួងអប់រំ ដើម្បីស្វែងរកដំណោះស្រាយដែលអាចធ្វើទៅបាន និងទទួលបានសារប្រយោជន៍សម្រាប់ទាំងអស់គ្នា ។

យើងសង្ឃឹមថា ក្នុងឱកាសទិវាគ្រូបង្រៀនពិភពលោកនេះ រាជរដ្ឋាភិបាល និងជាពិសេសក្រសួងអប់រំនឹងមើលឃើញសំណើនេះ គឺជាឱកាសដើម្បីរួមសហការណ៍ជាមួយសមាគមជាដៃគូក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់គុណភាពនៃការអប់រំនៅប្រទេសកម្ពុជា ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១១*

**ប្រធាន**

**រ៉ុង ឈុន**

***[ តមកពីទំព័រទី ១ ]***

លោក **ម៉ែន សុខផៃ** ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យខេត្តបាត់ដំបង បានសម្ដែងកិច្ចស្វាគមន៍ ចំពោះលោកគ្រូអ្នកគ្រូដែលមានវត្តមានក្នុងអង្គសិក្ខាសាលា និងថ្លែងអំណរគុណដល់សហជីពគ្រូបង្រៀននៃប្រទេសអង់គ្លេស (ATL) តែងតែជួយដល់គ្រូបង្រៀនកម្ពុជា ។

លោកក៏បានរាយការណ៍អំពីសកម្មភាពការងាររបស់សមាគមជូនអង្គសិក្ខាសាលាជ្រាប ។ ក្នុងនោះលោកក៏បានបញ្ជាក់ដែរថា សមាគមខេត្តបាត់ដំបងមានម៉ោងវិទ្យុ ចំនួន ២ម៉ោង ក្នុងមួយសប្ដាហ៍ផ្សាយតាមវិទ្យុ FM 92 MHZ ។

ជាមួយគ្នានេះលោកក៏បានសុំឱ្យសមាជិកសមាគមបង់ភាគទានជូនសមាគមឱ្យបានគ្រប់ៗគ្នា ។

លោកប្រធាន **រ៉ុង ឈុន** បានបង្ហាញ-ថា សមាគមខ្លាំងទៅបាន អាស្រ័យការចូលរួមពីលោកគ្រូអ្នកគ្រូទាំងអស់គ្នាធ្វើសកម្មភាព ផ្សព្វផ្សាយនូវគោលការណ៍សមាគម បង់ប្រាក់ភាគទានគាំទ្រសមាគម ទាំងអស់នេះជាភាពខ្លាំងរបស់សមាគម ដែលមិនអាចខ្វះបាន ។

លោក **ចន** ជាទីប្រឹក្សារបស់សមាគមបានធ្វើបទបង្ហាញអំពីការតស៊ូមតិរួចចែកជា៤ក្រុមដើម្បីធ្វើការពិភាក្សា ។



***លោក ម៉ែន សុខផៃ ប្រធានសមាគមគ្រូបង្រៀនខេត្តបាត់ដំបងកំពុងមានមតិ***

លោកគ្រូ **ឃឹម ហ៊ាន** តំណាងក្រុម៤ បានបកស្រាយលើប្រធានបទរបស់ក្រុមខ្លួនថា សាលារៀននិងសហគមន៍ តែងតែមានទំនាក់ទំនងជាមួយសិស្សនិងគ្រូបង្រៀនមិនអាចខ្វះបាន ។ សមាគមមានការឃ្លាតឆ្ងាយពីសាលារៀន ប៉ុន្តែបុគ្គលិកវិញមានទំនាក់ទំនងល្អជាមួយសមាគម ពីព្រោះសមាគមអាចជួយដល់ពួកយើងខ្ញុំជាបុគ្គលិកបាន ។

អ្នកគ្រូ **ឆែម ធឿត** តំណាងឱ្យក្រុម៣ បកស្រាយថា ការតស៊ូមតិមានការទំនាក់ទំនងនឹងគណបក្ស វត្ត សាលារៀន ។ ប៉ុន្តែគ្រប់យ៉ាង គឺស្ថិតនៅក្រោមអំណាចអាជ្ញាធរ និងអ្នកមានអំណាច ។

លោកគ្រូ **ម៉ាក់ វណ្ណាន** តំណាងឱ្យក្រុម២ បកស្រាយថា មន្ទីរអប់រំ មានទំនាក់ទំនងជាមួយសាលារៀន អង្គការក្រៅរដ្ឋាភិបាល គ្រូបង្រៀន អាជ្ញាធរ សិស្សព្រមទាំងសហគមន៍ ប៉ុន្តែជាមួយសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យវិញ មិនសូវមានឡើយ ។ ការដែលមិនមានទំនាក់ទំនងនេះហើយ ធ្វើឱ្យគ្រូយើងមានភាពភ័យខ្លាច ។ ការតស៊ូមតិធ្វើឱ្យគ្រូយើងមានភាពក្លាហាន បាត់នូវភាពភ័យខ្លាចបានមួយចំនួនធំ ។

លោកគ្រូ **ជួន ណារិន** តំណាងឱ្យក្រុម១ បកស្រាយថា រដ្ឋាភិបាលមានការទំនាក់ទំនងគ្រប់ស្ថាប័នទាំងអស់ ។ ហើយរដ្ឋាភិបាលគួរតែមើលលើវិស័យអប់រំសព្វថ្ងៃនេះផង ជាពិសេសបញ្ហាជីវភាពគ្រូបង្រៀនមិនគួរឱ្យគ្រូវេទនាបែបនេះទេ ។

ក្រោយពីក្រុមនីមួយៗធ្វើការបកស្រាយចប់ លោក **ចន** បានធ្វើការសម្របសម្រួលចំពោះបទបង្ហាញទាំងនេះបានយ៉ាងល្អ ។

ចុងបញ្ចប់លោកប្រធាន **រ៉ុង ឈុន** បានធ្វើការសរុបខ្លឹមសារនៃអង្គសិក្ខាសាលា និងថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់របស់លោកគ្រូអ្នកគ្រូនិងថ្លែងអំណរគុណដល់ម្ចាស់ជំនួយ (ATL) និងអាជ្ញធរដែនដី ដែលបង្កភាពងាយស្រួលដល់អង្គសិក្ខាសាលាថ្ងៃនេះ ។

***ដោយ : កញ្ញា កែវ រចនា***



***[ តមកពីទំព័រទី ៨ ]***

ចងក្រងនូវបណ្តាញ ឬរចនាសម្ព័ន្ធដឹកនាំ និងសម្ព័ន្ធភាព ។

ការតស៊ូមតិ គឺក្នុងគោលបំណងចង់ផ្លាស់ប្តូរនូវគោលនយោបាយ តួនាទីកម្មវិធីរបស់រដ្ឋាភិបាល លក្ខខណ្ឌការងារ ស្ថាប័ន និងបុគ្គលណាមួយ ។

ការផ្លាស់ប្តូរនេះ យើងត្រូវអនុវត្តតាមផែនការបែបណា ដែលស្របតាមស្ថានការណ៍សង្គមទើបមានប្រសិទ្ធភាព ។ ដើម្បីទទួលបានជោគជ័យ ត្រូវធ្វើការស្រាវជ្រាវ វិភាគ ធ្វើយុទ្ធនាការ ការ-ចងសម្ព័ន្ធភាព និងការបណ្តុះបណ្តាល ។

ការតស៊ូមតិឱ្យកាន់តែមានឥទ្ធិពលនោះ គឺគិតទៅលើផលប្រយោជន៍ សាធារណៈ ហើយនិងផលប្រយោជន៍ បុគ្គល ។

លោក **ចន** ធ្វើបទបង្ហាញចប់ ចែកជាក្រុមដើម្បីពិភាក្សាលើប្រធានបទតស៊ូមតិ ។ ក្រុមនីមួយៗបានធ្វើការបកស្រាយយ៉ាងយកចិត្តទុកដាក់ និងធ្វើការបញ្ចេញមតិយ៉ាងផុលផុស ។

ចំពោះការតស៊ូមតិនេះ លោក **ចន** បានបញ្ជាក់ថា យើងមានច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់អប់រំ និង អនុសញ្ញាអន្តរជាតិនានា ការពារនូវការសម្តែងមតិ និងការទាមទារតវ៉ាដោយស្របច្បាប់ ។



***លោកគ្រូអ្នកគ្រូកំពុងបញ្ចេញមតិក្នុងក្រុមពិភាក្សាស្តីពីការតស៊ូមតិ***

លោកប្រធាន **វ៉ុង ឈុន** បានធ្វើការសម្របសម្រួលដោយសុំឱ្យសមាជិកសមាជិកាទាំងអស់ខិតខំរកសមាជិកថ្មី និងការបង់ប្រាក់ភាពទាន ទោះជានៅកម្រិតតិចតួចក៏ដោយចុះ ។

ការបង់ភាគទានរបស់សមាជិក គឺបង្ហាញនូវភាពខ្លាំងរបស់សមាគម ។

ការរួមសាមគ្គីជាមួយសមាគម គឺជាការឈានឆ្ពោះទៅរកផលប្រយោជន៍ និងភាពថ្លៃថ្នូរក្នុងសង្គម ។ គ្រូមានអំណាចតាមរយៈការរួមគ្នាជាក្រុម ទើបអាចផ្លាស់ប្តូរនូវជីវភាពរស់នៅបែបសព្វថ្ងៃនេះបាន ។ បើគ្រូយើងមិនរួមគ្នាតវ៉ាទាមទារដោយខ្លួនឯងទេ ពុំមានការផ្លាស់ប្តូរឡើយ ។ បើយើងរងចាំអ្នកនយោបាយ គេមិនអាចជួយយើងបាននោះទេ ។ មានតែខ្លួនយើងទេ ទើបអាចជួយខ្លួនយើងបាន ។

មានតែអ្នកមានបញ្ហាទេ ដែលជាអ្នកដោះស្រាយបញ្ហា មានន័យថា បើគ្រូយើងមានបញ្ហាលំបាកផ្នែកជីវភាព ផ្នែកសេរីភាព ផ្នែកស្មារតី... ត្រូវតែរួមគ្នាដោះស្រាយបញ្ហាទាំងអស់គ្នា ក្នុងនាមក្របខណ្ឌជាគ្រូបង្រៀន តាមរយៈរួមគ្នាឱ្យទៅជាកម្លាំងតែមួយ សំឡេងតែមួយ រួចលើបញ្ហាស្នើទៅរាជរដ្ឋាភិបាលឱ្យដោះស្រាយជូនគ្រូបង្រៀនយើង ។

***ដោយ : ម៉ៃ សុភ័ត្រា***





***សកម្មភាពលោកគ្រូអ្នកគ្រូកំពុងពិភាក្សាជាក្រុមលើប្រធានបទការតស៊ូមតិ (ខេត្តស្វាយរៀង)***

# សមាគមស្នើសុំរាជរដ្ឋាភិបាលតម្លើងប្រាក់បៀវត្សរ៍ជូនដល់គ្រូបង្រៀនក្នុងកម្រិត ៩៥.២២ដុល្លារដល់២៥៩.៣៥ដុល្លារឡើងទៅ ចាប់ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៥

រាជរដ្ឋាភិបាលបានឧបត្ថម្ភ ២០% ដល់មន្ត្រីរាជការគ្រូបង្រៀនជារៀងរាល់ឆ្នាំនេះ មិនអាចឱ្យគ្រូបង្រៀន និងមន្ត្រីរាជការ មានជីវភាពធូរធារបាននោះទេ ក្នុងស្ថានភាពទំនិញនៅលើទីផ្សារកំពុងតែឡើងថ្លៃហួសហេតុនោះ ។

ការតម្លើង ២០% នេះ សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ បានធ្វើការសិក្សាទៅឃើញថាមានការឡើងតិចតួចបំផុត ដូចបញ្ជាក់នៅក្នុងតារាងខាងក្រោមនេះ :

**គម្រោងតម្លើងប្រាក់បៀវត្សរ៍គ្រូបង្រៀនរបស់រាជរដ្ឋាភិបាលចំនួន ២០% ចាប់ពីឆ្នាំ២០១២ ដល់ ២០១៥**

| | ឆ្នាំ២០១០ | ឆ្នាំ២០១១ | ឆ្នាំ២០១២ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ |
|---|---|---|---|---|---|---|
| **បឋមសិក្សា ២០%** | ៥០ដុល្លារ | ៦០ដុល្លារ | ៧២ដុល្លារ | ៨៦.៤០ដុល្លារ | ១០៣.៦៨ដុល្លារ | ១២៤.៤៦ដុល្លារ |
| **មធ្យមសិក្សាបឋមភូមិ ២០%** | ៧៥ដុល្លារ | ៩០ដុល្លារ | ១០៨ដុល្លារ | ១២៩.៦០ដុល្លារ | ១៥៥.៥២ដុល្លារ | ១៨៦.៦២ដុល្លារ |
| **មធ្យមសិក្សាទុតិយភូមិ ២០%** | ១០០ដុល្លារ | ១២០ដុល្លារ | ១៤៤ដុល្លារ | ១៧២.៨០ដុល្លារ | ២០៧.៣៦ដុល្លារ | ២៤៨.៨៣ដុល្លារ |

ក្នុងស្ថានភាពដែលទំនិញទីផ្សារកំពុងតែឡើងថ្លៃនេះ សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ បានធ្វើការស្នើសុំឱ្យរាជរដ្ឋាភិបាល តម្លើងប្រាក់បៀវត្សរ៍ជូនដល់គ្រូបង្រៀន ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ ក្នុងកម្រិតបឋមសិក្សាឱ្យបាន ៣៨% (៩៥.២២ដុល្លារ ដល់ ២៥០.២៣ដុល្លារ) កម្រិតមធ្យមសិក្សាបឋមភូមិឱ្យបាន ២៨% (១២២.៨៨ដុល្លារ ដល់ ២៥៧.៦៧ដុល្លារ) និងកម្រិតមធ្យមសិក្សាទុតិយភូមិឱ្យបាន ២១% (១៤៦.៤១ដុល្លារ ដល់ ២៥៩.៣៥ដុល្លារ) ឡើងទៅ ដូចមានក្នុងតារាងខាងក្រោមនេះ :

**សំណើរបស់សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA) តម្លើងប្រាក់បៀវត្សរ៍គ្រូបង្រៀន ចាប់ពីឆ្នាំ២០១២ ដល់ ២០១៥**

| | ឆ្នាំ២០១០ | ឆ្នាំ២០១១ | ឆ្នាំ២០១២ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ |
|---|---|---|---|---|---|---|
| **បឋមសិក្សា ៣៨%** | ៥០ដុល្លារ | ៦៩ដុល្លារ | ៩៥.២២ដុល្លារ | ១៣១.៤០ដុល្លារ | ១៨១.៣៣ដុល្លារ | ២៥០.២៣ដុល្លារ |
| **មធ្យមសិក្សាបឋមភូមិ ២៨%** | ៧៥ដុល្លារ | ៩៦ដុល្លារ | ១២២.៨៨ដុល្លារ | ១៥៧.២៨ដុល្លារ | ២០១.៣១ដុល្លារ | ២៥៧.៦៧ដុល្លារ |
| **មធ្យមសិក្សាទុតិយភូមិ ២១%** | ១០០ដុល្លារ | ១២១ដុល្លារ | ១៤៦.៤១ដុល្លារ | ១៧៧.១៥ដុល្លារ | ២១៤.៣៥ដុល្លារ | ២៥៩.៣៥ដុល្លារ |

# ប្រទេសកម្ពុជា ៖ ការវាយប្រហារលើសិទ្ធិគ្រូបង្រៀន

អង្គការពលកម្មអន្តរជាតិ (ILO) គឺជាគណៈដឹកនាំដ៏មានឥទ្ធិពលមួយ ដែលការលះបង់របស់អង្គការត្រូវបានទទួលស្គាល់ និងភ្ជាប់ទំនាក់ទំនងដោយសហជីពអប់រំដើម្បីការពារសិទ្ធិគ្រូបង្រៀន ។

ថ្វីបើមានការរិតត្បិតបង្ខាំងច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិដែលធ្វើឡើងដោយរាជរដ្ឋាភិបាលទៅលើសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ក៏ដូចជាសិទ្ធិក្នុងការចរចាជាសមូហភាពដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល(១៩៩៤) របស់ប្រទេសក៏ដោយ ក៏គ្រូបង្រៀន នៅតែបន្តបដិសេធន៍មិនទទួលយកការរិតត្បិតទៅលើសិទ្ធិនេះឡើយ ។ ច្បាប់នេះមានការរារាំងបុគ្គលិកបម្រើការងារវិស័យសាធារណៈទាំងអស់ ពី "ការបង្កើតសហជីព ឬពាក់ព័ន្ធជាមួយអនុសញ្ញារួមជាមួយរាជរដ្ឋាភិបាលឡើយ" ។

រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាកំពុងតែបន្តជៀសវាងកែទម្រង់ច្បាប់នេះ ដែលច្បាប់នេះរួមមានជាការចុះហត្ថលេខាអមដោយអនុសញ្ញា ILO លេខ ៨៧ និង ៩៨ និងការផ្តល់ជាអនុសាសន៍ក្នុងរបាយការណ៍របស់គណៈកម្មាធិការអង្គការ ILO លេខ ៣៣៤ និង៣៣៦ ស្តីពីសេរីភាពក្នុងការបង្កើតសមាគម ។ ចំណែកឯច្បាប់ស្តីពីការងារមិនបានគ្របដណ្តប់លើមន្ត្រីបម្រើការងារវិស័យសាធារណៈ ដែលស្តីអំពីគ្រូបង្រៀន គឺជាក្រុមមួយដ៏ធំជាងគេនោះ ប៉ុន្តែជាលទ្ធផល គឺមិនទទួលបានប្រយោជន៍អ្វីឡើយ នៅពេលដែលគ្រូបង្រៀនស្វែងរកការការពារ និងលើកកម្ពស់ពួកគេ ។

ការបដិសេធផ្តល់សិទ្ធិពេញលេញ គឺជាការរារាំងគ្រូបង្រៀនមិនឱ្យមានការបង្កើតសហជីព នៅក្នុងប្រទេសកម្ពុជា ដែលអាចត្រឹមតែចុះបញ្ជីមានឈ្មោះថា "សមាគម" នេះជាការកាត់បន្ថយឋានៈកិត្តិស័ព្ទនិងជាការដកសំឡេងគ្រូបង្រៀនចេញពីការចូលរួមដំណើរការការងារក្នុងការផ្លាស់ប្តូរទម្រង់វិស័យអប់រំនិងការចរចាជាសមូហភាព ។

សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ(CITA) បន្តព្យាយាមបញ្ចុះបញ្ចូលឱ្យមានការលើកកម្ពស់ឋានៈសហជីព តែទោះជាយ៉ាងណាក៏ដោយ យុទ្ធនាការនេះគឺមានភាពស្មុគស្មាញដោយសារថ្មីៗនេះ មានសេចក្តីព្រាងច្បាប់ពីរដែលត្រូវបានរៀបចំឡើងមុនឆ្នាំ២០១១ ។

**ទី១** : គឺសេចក្តីព្រាងច្បាប់អង្គការ និងសមាគម ។ ប្រសិនបើច្បាប់នេះត្រូវបានអនុម័ត វានឹងមានការជះឥទ្ធិពលមកលើសមាគម(CITA) ហើយនឹងដាក់បន្ទុកសង្កត់សង្កិនផ្នែកការងាររដ្ឋបាល ។

**ទី២** : សេចក្តីព្រាងច្បាប់សហជីពដែលថ្មីៗនេះ វាហាក់បីដូចជាការដកការចូលរួមរបស់បុគ្គលិកបម្រើការងារវិស័យសាធារណៈ ។ បើទោះបីណាជាច្បាប់នេះបានការកែសម្រួលក៏ដោយ ក៏នៅតែជាការចោទជាបញ្ហាចម្បងដែរ ជាពិសេសទាក់ទងជាមួយនឹងច្បាប់ការពារសហជីព ដោយសារមូលហេតុច្បាប់នេះមិនបានអនុវត្តរាប់បញ្ចូលខ្លឹមសារពេញលេញរបស់អនុសញ្ញា ILO លេខ ៨៧ នឹង ៩៨ ។ ច្បាប់នេះមិនត្រឹមតែជាការបដិសោធជាមួយគ្រូបង្រៀននូវសិទ្ធិសហជីពនោះទេ ថែមទាំងដកតួនាទីរបស់ពួកគេចេញជាអ្នកពាក់ព័ន្ធសំខាន់ក្នុងការអប់រំទៀតផង ។

សេចក្តីព្រាងច្បាប់អង្គការ និងសមាគម (គូសបញ្ជាក់ចំណុចមួយចំនួន) : **មាត្រា ១០** : តម្រូវឱ្យមានការពិចារណាអំពីព័ត៌មាននៃការរៀបចំការងារ រាប់បញ្ចូលទាំងការផ្តល់រូបថតគ្រប់អ្នកដឹកនាំអង្គការ ឬសមាគមនោះ ។

**មាត្រា ១៣** និង **២២** : តម្រូវឱ្យមានការបង់ថ្លៃចុះបញ្ជីកាដែលថ្លៃសេវាទាំងនេះអាចជាការហាមឃាត់អង្គការ និងសមាគមមួយចំនួនមិនអាចមានចុះបញ្ជីកាបាន ។

**មាត្រា ៣៦** : តម្រូវឱ្យអង្គការ និងសមាគមសហការជាមួយក្រសួងពាក់ព័ន្ធក្នុងការរៀបចំផែនការ និងអនុវត្តការងាររបស់ពួកគេ ។ នេះជាបញ្ហាចោទយ៉ាងខ្លាំងក្នុងការទទួលបានឯករាជ្យភាពរបស់ការងារអង្គការនិងសមាគម ។

**មាត្រា ៥២** និង **៥៤** : បង្កប់នូវការបដិសេធមិនឱ្យអង្គការនិងសមាគមអាចចុះបញ្ជីកាបាន ប៉ុន្តែមិនបានគូសបញ្ជាក់អំពីប្រព័ន្ធស្នើសុំ ដែលចុងក្រោយការសម្រេចចិត្ត នៅតែជាលទ្ធភាពរបស់រដ្ឋាភិបាល ។

សេចក្តីព្រាងច្បាប់សហជីព (គូសបញ្ជាក់ចំណុចមួយចំនួន) : បច្ចុប្បន្ននេះ មានការអំពាវនាវពីប្រជាពលរដ្ឋកម្ពុជា និងក្រុមសហជីពអន្តរជាតិឱ្យច្បាប់នេះមានវិសាលភាពលើមន្ត្រីរាជការកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងកម្មករបម្រើការងារតាមផ្ទះ ។

**មាត្រា ១៣** : ដាក់កំណត់រយៈពេលនៃការកាន់តំណែងរបស់អ្នកដឹកនាំសហជីព ។

**មាត្រា ២១** : បង្កើតការទាមទារយ៉ាងតឹងរឹងអំពីអាយុសញ្ជាតិ និងកម្រិតនៃការសិក្សាអប់រំរបស់មន្ត្រី និងបុគ្គលិករបស់សហជីព ។

សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA) បានចូលរួមធ្វើការយ៉ាងសកម្មក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើយុទ្ធនាការ ដើម្បីផ្លាស់ប្តូរទម្រង់សេចក្តីព្រាងច្បាប់ទាំងពីរនេះជាមួយសហជីពនិងអង្គការសង្គមស៊ីវិលនានា ។

សកម្មភាពមានដូចជាការបញ្ចូលសេចក្តីព្រាងច្បាប់នោះទៅកាន់គណៈកម្មការសន្និសីទរបស់អង្គការ ILO ស្តីពីការស្នើធ្វើឱ្យស្របទៅនឹងបទដ្ឋានរបស់អនុសញ្ញាអង្គការ ILO លេខ ៨៧ និង ៩៨ ។

# សិក្ខាសាលាស្ដីពីការបណ្ដុះបណ្ដាលអំពីការតស៊ូមតិ



***សកម្មភាពលោកគ្រូអ្នកគ្រូដែលជាសមាជិកសមាជិកាសមាគមខេត្តស្វាយរៀងចូលរួមក្នុងអង្គសិក្ខាសាលា***

សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យខេត្តស្វាយរៀង បានរៀបចំសិក្ខាសាលាស្ដីពី ការអប់រំចំណេះដឹង និងបណ្ដុះបណ្ដាលអំពីការតស៊ូមតិ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ នៅសណ្ឋាគារវ៉ៃកូ ក្រុងស្វាយរៀង ខេត្តស្វាយរៀង ក្រោមអធិបតីភាពលោកប្រធាន **រ៉ុង ឈុន** និងលោក **ចន** ទីប្រឹក្សាសមាគម មានវត្តមានលោកគ្រូអ្នកគ្រូចូលរួមចំនួន ២៩ នាក់ ។

សិក្ខាសាលានេះមានការជួយឧបត្ថម្ភពីសហជីពគ្រូបង្រៀនអង់គ្លេស (ATL) ។

ជាកិច្ចចាប់ផ្ដើមលោក **មាស ឈី** ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យខេត្តស្វាយរៀង បានស្វាគមន៍ ចំពោះវត្តមានលោកប្រធានសមាគម និងលោក **ចន** ទីប្រឹក្សាសមាគម ព្រមទាំងលោកគ្រូអ្នកគ្រូដែលមានវត្តមាននៅក្នុងសិក្ខាសាលានាពេលនេះ ។ សិក្ខាសាលាថ្ងៃនេះផ្ដោតសំខាន់ទៅលើរបៀបតស៊ូមតិ ធ្វើបទបង្ហាញ ដោយលោក **ចន** បកប្រែដោយកញ្ញា **កែវ រចនា** ។ ជាមួយគ្នានេះក៏យើងមិនភ្លេចពង្រឹងនូវការងារស្នូលរបស់សមាគមយើងដែរ គឺការពង្រីកសមាជិកថ្មី ជំរុញការបង់ភាគទានរបស់សមាជិក ដើម្បីទ្រទ្រង់សមាគម ។

លោកប្រធាន **រ៉ុង ឈុន** បានថ្លែងថា គ្រប់សមាជិកសមាគមត្រូវតែយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយនូវគោលនយោបាយរបស់សមាគម និងជំរុញឱ្យសមាជិកបង់ភាពទាន ដូចលោក **មាស ឈី** បានជម្រាបជូនខាងលើ ។

សមាគមមានលក្ខណៈខុសគ្នាពីអង្គការបម្រើសេវាត្រង់ថា អង្គការបម្រើសេវាគ្រាន់តែផ្ដល់ជាសម្ភារៈ ឬអប់រំបណ្ដុះបណ្ដាលរួចចប់ហើយ ប៉ុន្តែសមាគម គឺត្រូវការចូលរួមគាំទ្រពីសមាជិក ដើម្បីរកផលប្រយោជន៍ជូនសមាជិក ទាមទារកែលំអនូវលក្ខខណ្ឌការងារ ការពារសិទ្ធិសេរីភាពជូនសមាជិក ហើយចូលរួមធ្វើចលនាយ៉ាងសកម្មជាមួយសមាគម ។

លោក **ចន** បានធ្វើការបកស្រាយ និងពន្យល់អំពីរបៀបតស៊ូមតិ ដើម្បីទទួលបានជោគជ័យ ត្រូវចេះធ្វើផែនការ និងចែករំលែកនូវព័ត៌មានសំខាន់ៗអំពីច្បាប់ទៅកាន់សមាជិក ព្រមទាំង

***[ តទៅទំព័រទី ៩ ]***